ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

នាយកដ្ឋានព័ត៌មាន

# សេចក្តីជូនព័ត៌មាន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នឹងដឹកនាំគណៈប្រតិភូជាន់ខ្ពស់អញ្ជើញចូលរួមកិច្ចប្រជុំកំពូលពិសេសរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-ឥណ្ឌា និងពិធីអបអរទិវាសាធារណរដ្ឋលើកទី៦៩ នៅទីក្រុងញូវ ដេលី និងបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋឥណ្ឌា ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ២៥ ដល់ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០១៨ តបតាមការអញ្ជើញរបស់**ឯកឧត្តម ណារិនដ្រា ម៉ូឌី** (Narendra Modi) នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋឥណ្ឌា។

ឥស្សរជនកម្ពុជាដែលនឹងអញ្ជើញអមដំណើរសម្តេចតេជោនាយករដ្ឋមន្ត្រី រួមមាន ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឯកឧត្តម សាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ឯកឧត្តម បណ្ឌិត ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ព្រមទាំងសមាជិកដ៏ទៃទៀតនៃរាជរដ្ឋាភិបាលកម្ពុជា។

ក្រៅពីការអញ្ជើញចូលរួមក្នុងកិច្ចប្រជុំកំពូលពិសេសរំលឹកខួបអនុស្សាវរីយ៍ អាស៊ាន-ឥណ្ឌា សម្តេចតេជោនាយករដ្ឋមន្ត្រី នឹងអញ្ជើញចូលរួមពិសារអាហារពេលព្រឹកការងារជាមួយនឹង ឯកឧត្តម ង្វៀន សួនហ៊្វុក នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងឯកឧត្តម ថងលូន ស៊ីស៊ូលីត នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

ក្នុងឱកាសកិច្ចប្រជុំកំពូលពិសេសនេះ សេចក្តីថ្លែងការណ៍ទីក្រុងញូវដេលី នឹងត្រូវបានអនុម័ត។

នៅក្នុងក្របខ័ណ្ឌនៃដំណើរទស្សនកិច្ចផ្លូវការ សម្តេចតេជោ ហ៊ុន សែន នឹងអញ្ជើញចូលជួបសម្តែងការគួរសមដាច់ដោយឡែកពីគ្នា ជាមួយ ឯកឧត្តម ស្រ៊ី រ៉ាម ណាត កូវិនដ៍ (Shri Ram Nath Kovind) ប្រធានាធិបតីឥណ្ឌា និងឯកឧត្តម ស្រ៊ី ម. វេនកៃអាហ៍ ណៃឌូ (Shri M. Vekaiah Naidu) អនុប្រធានាធិបតីឥណ្ឌា ក៏ដូចជានឹងទទួលជួបសម្តែងការគួរសមដោយលោកជំទាវ ស៊ូសម៉ា ស្វារ៉ាជ (Sushma Swaraj) រដ្ឋមន្ត្រីការបរទេសឥណ្ឌា ។ សម្តេចតេជោក៏នឹងអញ្ជើញដាក់កម្រងផ្កានៅស្តូបគោរពវិញ្ញាណក្ខន្ធ លោក មហាត្មៈ គន្ធី ផងដែរ។

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

សម្តេចតេជោ ហ៊ុន សែន នឹងជួបប្រជុំទ្វេភាគីជាមួយ ឯកឧត្តម ណារិនដ្រា ម៉ូឌី នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋឥណ្ឌា។ បន្ទាប់មកថ្នាក់ដឹកនាំប្រទេសទាំងពីរ នឹងអញ្ជើញធ្វើជាអធិបតីក្នុងពិធីចុះហត្ថលេខាលើឯកសារនៃកិច្ចសហប្រតិបត្តិការទ្វេភាគីមួយចំនួនហើយនឹងបន្តដោយការធ្វើសន្និសីទសារព័ត៌មានរួមគ្នា។

នៅក្នុងឱកាសស្នាក់នៅប្រទេសឥណ្ឌា សម្តេចតេជោនាយករដ្ឋមន្ត្រី ក៏នឹងអញ្ជើញថ្លែងសុន្ទរកថាគន្លឹះនៅឯវេទិកាធុរៈកិច្ចឥណ្ឌា-កម្ពុជា ផងដែរ។

ថ្ងៃ ចន្ទ ៦កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែមករា ឆ្នាំ២០១៨